# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងសភាព្រហ្មទណ្ឌ
លេខៈ ៧២១ / ២៣-០៧-២០១២
សាលដីកា
[redacted]ខៈ៤៦ក្រVIIធ/១២.០៩.២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

៣៣៣✵៤៤៤

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦.៧.២០១៤ បាន បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី១២.០៩.២០១៤ដែលមាន សមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សា</u>**

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ចៅក្រមប្រឹក្សា |
| លោក | [redacted] | ចៅក្រមប្រឹក្សា |

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ៧២១ ចុះថ្ងៃទី ២៣-០៧-២០១២ រវាងៈ

១-ឈ្មោះ [redacted]អឿន ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតខេត្ត[redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោ[redacted](ស) ម្តាយឈ្មោ[redacted](ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ១០ថ្ងៃ ។

២-ឈ្មោះ [redacted] សុម៉ាលី ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតខេត្ត[redacted] ទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះអ៊ុក ឈុំ (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted]ទោសពីមុនគ្មាន ។

*<u>ត្រូវចោទពីបទៈ</u>* ហឹង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ១ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រម ព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោ[redacted] ភេទស្រី អាយុ៦២ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នក្រុមទី[redacted]

**<u>៦រឿងហេតុមានដូចតទៅៈ</u>**

កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោង១០:០០នាទី ស្ថិតនៅភូមិ១ សង្កាត់៤ ក្រុងព្រះសី

ហនុ ខេត្តព្រះសីហនុ មានករណីប្រើហិង្សាដោយចេតនា មួយកើតឡើងបង្កដោយឈ្មោះ [redacted] សុម៉ាលី ភេទស្រី និងឈ្មោះ [redacted] អឿន ភេទប្រុស បានធ្វើសកម្មភាពវាយប្រតាយប្រតប់ទៅលើឈ្មោះ [redacted] ចាន់ណា ដោយចាប់ទាញអុកនិងគ្រែមួលក បោចសក់ដាល់ថ្ពាស និងខ្វាចដៃបណ្ដាលឲ្យជាំឈាមលើគូថខាងស្ដាំ ឈឺចុកចាប់ពេញខ្លួន ហើយនិងគំរាមថាថ្ងៃនេះ វ៉ៃប៉ុណ្ណឹង ថ្ងៃក្រោយវ៉ៃលើសហ្នឹងទៀត និងប្រយ័ត្នបាត់ខ្លួនទៀតផង។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] សុម៉ាលី បានឆ្លើយនាពេលសវនាការ នៅចៅក្រមស៊ើបសួរ នៅអយ្យការ និង នៅសមត្ថកិច្ចប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនគ្រាន់តែបានចាប់ដៃយាយពែកចេញកុំឲ្យជេរខ្លួននៅមុខផ្ទះគេ ពេលនោះយាយពែកក៏របូតជើងធ្លាក់ពីលើគ្រែអត់មានអុកគូថអ្វីទាំងអស់ ខ្លួនមិនបានទាញយាយពែកអុកនៅនឹងគ្រែអុកគូថ មួលកបោចសក់ ដាល់ថ្ពាស និងបបូរមាត់ដូចដែលគាត់និយាយនោះទេ។ រូបថតដែលតុលាការបង្ហាញខ្លួន ឃើញស្នាមរបួសថ្ពល់ខាងឆ្វេងរបស់យាយពែក ពិតជាកើតពេលខ្លួនប្រតាយប្រតប់គ្នាជាមួយយាយពែក ចំពោះរូបថតដែលតុលាការបង្ហាញស្នាមរបួសត្រង់គំប៉េះគូថខាងស្ដាំនោះពុំមានក្នុងពេលប្រតាយនោះទេ។ ចំពោះប្ដីខ្លួនមិនបានវាយតប់យាយពែក នៅពេលកើតហេតុទេ គាត់គ្រាន់តែដើរទៅចាប់ទាញខ្លួនចេញមកផ្ទះតែប៉ុណ្ណោះ។

-បានឃើញចម្លើយជនជាប់ចោទឈ្មោះ [redacted] អឿន ឆ្លើយនៅចៅក្រមស៊ើបសួរ និងនៅអយ្យការប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃខែមិនចាំឆ្នាំ២០១១ វេលាម៉ោងប្រហែល ៦:៣០នាទីយប់ ប្រពន្ធខ្លួនបានប្រើកូនឲ្យទៅទារលុយគេ ដើរកាត់ផ្ទះយាយពែក ស្រាប់តែវាដើរត្រឡប់មកវិញ ហើយប្រាប់ថាយាយពែកបង្អើលឆ្កែឲ្យដេញខាំ ប្រពន្ធខ្លួនក៏និយាយថា សូម្បីតែក្មេងក៏មានគំនុំដែរ ហើយគាត់និយាយថា ដីឡូត៍របស់គាត់មិនឲ្យដើរកាត់ទេ រួចគាត់ដើរមកក្បែរគ្រែមុខផ្ទះពូខន ពេលនោះប្រពន្ធខ្លួនក៏ដើរចេញពីផ្ទះទៅសួរគាត់ថា កូនខ្លួនមានរឿងអីបានជាបង្អើលឆ្កែឲ្យខាំវា ពេលនោះយាយពែកឆ្លើយថា ដីរបស់អញៗមិនឲ្យដើរទេ ពេលនោះប្រពន្ធខ្លួនក៏ចាប់ដៃយាយពែកអូសចេញពីផ្ទះពូខន ដើម្បីសួរនាំឲ្យដឹងរឿង ហើយខ្លួនក៏ចូលទៅចាប់អូសដៃប្រពន្ធខ្លួនឲ្យត្រឡប់មកផ្ទះវិញ ចំពោះយាយពែក ក៏ដើរត្រឡប់ទៅផ្ទះគាត់វិញដែរ។ថ្ងៃកើតហេតុនោះខ្លួនមិនបានវាយតប់ទៅលើយាយពែកទេ សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង។

-បានឃើញចម្លើយជនរងគ្រោះឈ្មោះ [redacted] ចាន់ណា ឆ្លើយនាពេលសវនាការ នៅចៅក្រមស៊ើបសួរ នៅអយ្យការ និងនៅសមត្ថកិច្ចប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃ២៦ ខែមិថុនា ឆ្នាំ២០១១ វេលាម៉ោងប្រហែល ៨ រឺ ៩ យប់ កូនរបស់ឈ្មោះ [redacted] សុម៉ាលី ដែលមានឈ្មោះ អើ អាយុប្រហែលជា ១៤ឆ្នាំ ភេទប្រុស បានដើរពីផ្ទះវាឆ្លងកាត់ផ្ទះរបស់ខ្លួនទៅក្រោយដោយខ្លួនប្រាប់ថា កុំដើរកាត់ឆ្កែកាចណាស់ប្រយ័ត្នវាខាំ ព្រោះម៉ែហ្អែងពូកែឈ្លោះណាស់អញឈ្លោះមិនឈ្នះទេ រួចវាក៏ដើរទៅផ្ទះវិញ។ ស្រាប់តែម្ដាយរបស់វាឈ្មោះ [redacted] សុម៉ាលី ស្រែកជេរខ្លួនចេញពីផ្ទះថា មីចោរគេចុយ មីចុយម្រាយ មីទំពែក ង៉ែងម៉េចមិនឲ្យគេដើរចេញមកនេះអញវាយង៉ែងឲ្យបែកក្បាលហ្នឹង ដោយខ្លួនមិនបានចេញពីផ្ទះទេ នៅឈរមាត់ទ្វារ។ បន្ទាប់មកខ្លួនដើរទៅតូបលក់កាហ្វេ និងទឹកកកឈូស ក្បែរផ្ទះខ្លួនស្រាប់តែពេលនោះឈ្មោះ [redacted] សុម៉ាលី ស្ទុះចេញពីផ្ទះទាញខ្លួនអុកនៅនឹងគ្រែអុកគូថ មួលកបោចសក់ ដាល់ថ្ពាស និងបបូរមាត់ សព្វពេញខ្លួន ខ្លួនមិនមានកំលាំងតបតទេ ស្រាប់តែពេលនោះដែរក៏ប្ដីរបស់ឈ្មោះ [redacted] សុម៉ាលី ឈ្មោះ [redacted] អឿន ចាប់ប្រពន្ធចេញហើយច្រានខ្លួន៕/

អុកគូថនៅនឹងគ្រែម្តងទៀត បណ្តាលឲ្យបែកឈាមជាំលើគូថខាងស្តាំ និង ក្រោយពីវាយរួចពួកគេត់រាមខ្លួនទៅប្តឹងទៅវ៉ែងចាស់ហើយគ្មានអ្នកណាធ្វើការឲ្យវ៉ែងទេ ថ្ងៃនេះវាយប៉ុននឹងថ្ងៃក្រោយវាយលើសហ្នឹងទៀតប្រយ័ត្នបាត់ខ្លួន។ក្នុងរឿងនេះខ្លួនសុំទាមទារសំណងជម្ងឺចិត្ត និងថ្លៃព្យាបាលបុសចំនួនប្រាំមួយលានរៀល។

-បានឃើញចម្លើយសាក្សីឈ្មោះ [redacted] មីនា ឆ្លើយនាពេលសវនាការ នៅថៅក្រមស៊ើបសួរ នៅអយ្យការ និងនៅសមត្ថកិច្ចប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃទី២៦ មិថុនា ឆ្នាំ២០១១ វេលាម៉ោង ៦ ឬ ៧ យប់ ខ្លួននៅផ្ទះតែម្នាក់ឯង ស្រាប់តែឃើញយាយពែក គាត់មកអង្គុយនៅលើគ្រែនៅមុខផ្ទះខ្លួនពេលនោះខ្លួនក៏ឃើញឈ្មោះ លី នៅមុខផ្ទះខ្លួនបានស្រែកជេរឈ្មោះ យាយពែក តែយាយពែកគាត់មិនបានជេរតទៅវិញទេស្រាប់តែឈ្មោះ លី ស្ទុះមកវាយយាយពែក ទម្លាក់ពីលើគ្រែរួចជិះពីលើ ពេលនោះស្រាប់តែប្តីរបស់ឈ្មោះ លី មកដល់ចាប់ទាញប្រពន្ធចេញ និងច្រានយាយពែកចេញដែរ រួចក៏នាំប្រពន្ធទៅផ្ទះវិញ។ ចំពោះរឿងដំបូងកូនរបស់ឈ្មោះលី ដើរកាត់ផ្ទះរបស់យាយពែក ហើយយាយពែកថាកុំឲ្យដើរកាត់ខ្លាចឆ្កែខាំ រួចកូនរបស់ឈ្មោះ លី ទៅប្រាប់ម្តាយហើយក៏មានការជេរ និងវាយគ្នាតែម្តងទៅ។

<u>-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៤(គ) ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលបានសម្រេចសេចក្តី ដូចខាងក្រោមៈ</u>

វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុម៉ាលី ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ចាន់ណា មេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អឿន តែចាត់ទុកជាចំពោះមុខ។

១.ផ្តន្ទាទោសលើឈ្មោះ [redacted] សុម៉ាលី ភេទស្រី អាយុ៣០ឆ្នាំ សាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល០១(មួយ) ឆ្នាំ តែទោសនេះព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលានរៀល) ចូលជាថវិការរដ្ឋ។

២.ផ្តន្ទាទោសលើឈ្មោះ [redacted] អឿន ភេទប្រុស អាយុ៣២ឆ្នាំ សាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល០២(ពីរ) ឆ្នាំ តែទោសនេះព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលានរៀល) ចូលជាថវិការរដ្ឋ។

ពីបទៈហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ១ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា២១៧ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

៣.បង្គាប់ឲ្យឈ្មោះ [redacted] អឿន និងឈ្មោះ [redacted] សុម៉ាលី រួមគ្នាសងថ្លៃព្យាបាល និងជំងឺចិត្តជាប្រាក់រៀលចំនួន ៥០០.០០០៛ (ហាសិបម៉ឺនរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ណា។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុម៉ាលី ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ចាន់ណា មេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អឿន តែចាត់ទុកជាចំពោះមុខ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញពាក្យបណ្តឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី៣១-០១-២០១២ របស់ឈ្មោះ [redacted] សុម៉ាលី./

និងឈ្មោះ[redacted]អឿន ប្តឹងមិនសុខចិត្តនិងសាលក្រមទាំងមូល។

**-បានឃើញ**របាយការណ៍ចុះថ្ងៃទី២៧-០៩-២០១២របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

**-បានឃើញ**សេចក្តីសន្និដ្ឋានចុះថ្ងៃទី០៣-១២-២០១២ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]សុម៉ាលី (អវត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted]អឿន (អវត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ[redacted](វត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង និងអានសេចក្តីសម្រេចរបស់សាលាដំបូងខេត្តព្រះសីហនុ

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]អឿន និងចម្លើយរបស់ឈ្មោះ[redacted]សុម៉ាលី

-តំណាងមហាអយ្យការសន្និដ្ឋាន:

តាមចម្លើយរបស់ជនជាប់ចោទពិតជាបានប្រព្រឹត្តមែន សាលាដំបូងខេត្តព្រះសីហនុបានសម្រេចក្តីមកនេះសមស្របតាមអង្គហេតុ និងគតិច្បាប់ហើយ ហេតុនេះសុំតំកល់សាលក្រមលេខ០៤(គ) ចុះថ្ងៃទី១៨-០១-២០១២ ទុកនៅដដែល។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់។

## សាលាឧទ្ធរណ៍យល់ឃើញថា:

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០១-២០១២របស់ឈ្មោះអ៊ុក សុម៉ាលី និងគ្រង់ អឿន ធ្វើឡើងតាមកំណត់ច្បាប់សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមបញ្ញត្តិមាត្រា ៣៧៥ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តាមចម្លើយរបស់ជនជាប់ចោទ តាមការបំភ្លឺរបស់សាក្សី បានបញ្ជាក់ឲ្យឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ[redacted] សុម៉ាលី បានប្រើកូនអោយទៅទារលុយគេ ដោយដើរកាត់ផ្ទះជនរងគ្រោះឈ្មោះ[redacted]ចាន់ណា ហៅយាយពែក ស្រាប់តែកូននោះដើរត្រឡប់មកវិញ ដោយប្រាប់ថាយាយពែកបង្អើលឆ្កែអោយដេញខាំ។ពេលនោះជនជាប់ចោទឈ្មោះ[redacted] សុម៉ាលី បានទៅជេរប្រមាថ និងវាយតប់ទៅលើជនរងគ្រោះឈ្មោះ[redacted]ចាន់ណា ហៅយាយពែក បណ្តាលឲ្យរងរបួសលើផ្ទៃមុខ។បន្ទាប់មកជនជាប់ចោទឈ្មោះ[redacted] អឿន បានទៅចាប់ទាញដៃប្រពន្ធឈ្មោះ[redacted]សុម៉ាលីចេញ និងបានច្រានជនរងគ្រោះឈ្មោះ[redacted]ចាន់ណា ចេញ បណ្តាលអោយជនរងគ្រោះអុកគូថ បណ្តាលឲ្យរងរបួសស្នាម។

៣-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] សុម៉ាលី និង[redacted] អឿន ពីបទហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ១ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៦-០៦-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៤-រឿងក្តីនេះសាលាដំបូងខេត្តព្រះសីហនុបានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូន

សព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំ-អាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ០៤(គ) ចុះថ្ងៃទី១៨-០១-២០១២ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

**ហេតុដូចនេះវិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០១-២០១២ របស់ឈ្មោះ [redacted] សុម៉ាលី និង [redacted] អឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៤(គ) ចុះថ្ងៃទី ១៨-០១-២០១២ របស់សាលាដំបូងខេត្ត ព្រះសីហនុ ទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះនិងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្រ្តីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងគ្រប់កំលាំងប្រដាប់អាវុធ ជួយសហការណ៍អនុវត្តសាលដីកានេះឲ្យបានសំរេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] - [redacted] | [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៥
ក្រឡាបញ្ជី
[redacted]